# ការបង្កហេតុ (Provocation)

១. ក្នុងរឿងព្រហ្មទណ្ឌ ទោះបីជាជនជាប់ចោទបានប្រព្រឹត្តបទល្មើសក្តី គាត់ក៏អាចមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដោយសារ យុត្តិកម្ម (justification) ឬ ការដោះសារ (excuse) ឬទទួលខុសត្រូវក្នុងកម្រិតណាមួយ (diminished responsibility: DR)។ ការបង្កហេតុ (Provocation) ជាមូលដ្ឋានមួយ នៃ DR និងមានប្រភពពីប្រព័ន្ធកំមុនឡ។

២. ការបង្កហេតុ អាចជាសកម្មភាព ឬ សំដី (ក្មេងស្រែកយំខ្លាំងៗរំខាន)។ លោក *ក* បង្កហេតុធ្វើឲ្យ លោក *ខ* តបត។ ក្នុងករណីខ្លះ សកម្មភាពឆ្លើយតបធ្វើឡើងលើជនទីបី ដែលមិនមែនជាអ្នកបង្ក។ ឧទាហរណ៍ សាហាយស្មន់របស់ប្រពន្ធ បានធ្វើឲ្យប្តីខឹង ហើយបានសម្លាប់ប្រុសកំណាន់របស់ប្រពន្ធ។ ការតបទៅនឹងការបង្កហេតុ តម្រូវឲ្យកើតមានភ្លាមៗ។ ប្រសិនបើមិនដូចនេះទេ វាអាចជាការសងសឹក បង្កហិង្សា នាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ។

៣. សកម្មភាពតបតនឹងការបង្កហេតុ នាំឲ្យបន្ថយការទទួលខុសត្រូវ លុះត្រាការបង្កហេតុនេះធ្ងន់ធ្ងរ និងនាំឲ្យបាត់បង់ការគ្រប់គ្រង (extreme and loss of control)។ សកម្មភាពបង្កត្រូវបានពិចារណាផ្អែកតាមអត្តនោម័ត (subjective Consideration)។ ការពិចារណា នូវការតបត ដោយសារបាត់បង់នូវការគ្រប់គ្រង ផ្អែកតាមសត្យានុម័ត (objective consideration) និងស្តង់ដាមនុស្សមានហេតុផល (reasonable person)។

៤. អ្នកបង្កហេតុ ដែលជាជនរងគ្រោះ គាត់ក៏អាចប្រើសិទ្ធិតបតវិញបានដែរ ក្នុងករណី ដែលការបង្កហេតុរបស់គាត់ មិនធ្ងន់ធ្ងរជាងការបង្កហេតុនៃជនល្មើស។ ក្នុងខ្លឹមសារនេះ ការបង្កហេតុ អាចជាប់ពាក់ព័ន្ធ នឹងអង្គហេតុ នៃ ការការពារខ្លួនផងដែរ (self-defence)។

៥. មានការវិវត្តផ្អែកទ្រឹស្តីមួយ ដែលហៅថា ៖រោគសញ្ញានៃស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ( Battered Women Syndromes: BWS) ដែលទំនងជាមិនចូលក្នុង លក្ខណវិនិច្ឆ័យនៃការបង្កហេតុទេ។ ក្នុងករណីនេះ ពេលវេលាអំឡុង ដែលស្ត្រីតបត និង ស្ថានភាពផ្លូវចិត្តរបស់នាងអាចមិនបាត់បង់ការគ្រប់គ្រងទេ។ ក៏ប៉ុន្តែ ដោយសារការបារម្ភ ខ្លាចការវាយដំដែលជាទម្លាប់របស់ប្តីនាពេលស្រវឹងស្រា នាងធ្វើការតបតជាមុន (pre-emptive strike)។ គេអាចអះអាងថា ហិង្សាជាទម្លាប់មកលើនាង ជាការបង្កហេតុ ដែលអាចនាំឲ្យនាងអាចច្រឡំថា នឹងមានការវាយដំដោយប្តី (ការច្រឡំអង្គហេតុ) https://www.bakc.org.kh/LegalDocument/Layout23.pdf ។ គេគួរកត់សំគាល់ថា ការវាយប្រហារបង្កាជាមុន មានភាពចំរូងចម្រាស់ ក្នុងបរិបទនៃ self-defence។ ទោះបីជាយ៉ាងនេះក្តី យុត្តាធិការរបស់ប្រទេសខ្លះ ទទួលយកវាយប្រហារបង្កា របស់នារីរងគ្រោះ ជាមូលដ្ឋានបន្ថយទោស។ ក្រៅពីនេះ តុលាការរដ្ឋខ្លះ ប្តូរបទចោទ ពី មនុស្សឃាតគិតទុកជាមុន មកជាមនុស្សឃាតចេតនា នៅក្នុងករណីមានការសម្លាប់ដោយការតបត។

<u>**កំណត់សំគាល់**</u>៖ ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩ មានចែងអំពីមូលដ្ឋានរួចផុតពីការទទួលខុសត្រូវ៖ **ក**. វិបល្លាសស្មារតី (insanity) មាត្រា ៣១។ **ខ**. អនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ (មាត្រា

៣២)។ **គ**. ការការពារស្របច្បាប់ (self-defence) មាត្រា ៣៣។ **ឃ**. សច្ចធារណ៍នៃការការពារស្របច្បាប់ (មាត្រា ៣៤)។ **ង**. ស្ថានភាពចាំបាច់ (state of Necessity) មាត្រា ៣៥។ **ច**. អានុភាពនៃកម្លាំង ឬការបង្ខំ (duress) មាត្រា ៣៥។ ដូចនេះ មិនមានចែងអំពី ការបង្កហេតុ ដែលអាចជាមូលដ្ឋានរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ឬ បន្ថយការទទួលខុសត្រូវទេ។

**ឯកសារយោង**៖ 1. Catherine Elliott and Frances Quinn, Criminal Law, 2006, pp. 73-80; 2. Kevin Jon Heller and Markus D. Dbber, the Handbook of Comparative Criminal Law, 2011, pp. 277, 341, 408; and 3. Alan Reed and Michael Bohlander, General Defenses in Criminal Law, 2014, pp.200, 276, 303.